សកម្មភាព ៖ **ល្បែងបន្ទាត់ទំនាក់ទំនង**

ចិត្តចលភាព

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

បំណិនចលកធំ(ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)។

សិក្សាសង្គម

ការយល់ដឹងពីតម្លៃមនុស្ស (កម្លាំង និងការយល់ដឹង និងចរិកលក្ខណៈមនុស្ស)

ភាសាខ្មែរ

ការយល់ដឹងពីភាសាដទៃ(ការយល់ដឹងការប្រើភាសាខុសគ្នាសម្រាប់ប្រាស្រ័យទាក់ទងគ្នាក្រៅពីភាសាផ្ទាល់ខ្លួន)

ការសន្ទនា(សន្ទនាដោយប្រើពាក្យ ឬ ឃ្លាត្រូវតាមវ័យ ភាសាបង្ហាញអារម្មណ៍ និងមនោសញ្ចេតនា)

គោលបំណង ៖

(ចិត្តចលភាព) ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។
បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

(សិក្សាសង្គម) ប្រាប់បានពីរការគោរពចាស់ទុំ។

(ភាសាខ្មែរ) ប្រាប់បាននៅឈ្មោះភាសាផ្សេងៗគ្នាដែលគេកំពុងនិយាយក្រៅពីភាសាកំណើតរបស់ខ្លួន។
ប្រាប់បានពណ៌មានផ្ទាល់ខ្លួន ឬ ព្រឹត្តិការណ៍ផ្សេងៗដែលបានជួបតាមលំដាប់លំដោយនៃសាច់រឿង។ សួរសំណួរ និងទទួលព័ត៌មានត្រលប់មកវិញ។

សៀវភៅ ៖ ដកស្រង់ចេញពីរឿង "យក្សចម្លែក"

រយៈពេល ៖ ១៥ នាទី

ឧបករណ៍ ៖ បាស ចម្រៀង និងពាក្យដែលត្រូវនិយាយ។

ការរៀបចំ ៖ រៀបចំសំណួរ ៤សំណួរ មានជាភាសាអង់គ្លេស និងភាសាខ្មែរ។

សេចក្តីណែនាំ៖

1. និយាយ៖ ថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងបន្ទាត់ទំនាក់ទំនង**ជាមួយកូនៗទាំងអស់គ្នា។
2. តែកូនៗត្រូវឈរជាជួរឱ្យដូចបន្ទាត់(ត្រូវជួយបែងចែកក្មេងៗឱ្យឈរជាជួរដូចបន្ទាត់)។
3. ១ជួរ ឬ ១ក្រុម ៥នាក់តាមស្ថានភាពជាក់ស្តែង។
4. និយាយសំណង់ប្រយោគសំណួរ ហើយឱ្យក្មេងៗថាតាម ឬ ពន្យល់ជាភាសាខ្មែរសិន។

1.សួស្តី! តើអ្នកសុខសប្បាយដែរឬទេ?

បាទ ខ្ញុំសុខសប្បាយទេ។

2.សួស្តី! តើអ្នកឈ្មោះអ្វីដែរ?

បាទ ខ្ញុំឈ្មោះ….

៣.ជម្រាបលា! ជួបគ្នាពេលក្រោយ!

ជម្រាបលា! ជួបគ្នាពេលក្រោយ!

(រីករាយដែលបានស្គាល់អ្នក ប្រសិនបើមាន)

ភាសាសួស្តីគ្នាជាភាសាអង់គ្លេស
Questions in English
1.Hello! How are you?
I am fine. Thank you ។
2.Hello! What is your name?
I am ….
៣.Good bye ! See you soon!
Good bye ! See you soon!
Nice to meet you.

5. អ្នកគ្រូចាប់ផ្តើមសួរសំណួរប្រយោគទាំងនោះតាមជួរ ឬ ក្រុមនីមួយៗរហូតក្មេងៗចងចាំ ។

ការប្រែប្រួលៈ
ប្រសិនបើមានក្មេងៗគាត់មានកម្រិតខ្ពស់ ពួកគេអាចងាកទៅរកគ្នាបានហើយនិយាយស្វាគមន៍ជំនួសឱ្យលោកគ្រូ អ្នកគ្រូបានទៅតាមជួរ ហើយនិយាយពាក្យស្វាគមន៍។ ល្បែងនេះអាចប្រែទៅជាការប្រណាំងមួយ ដែលក្មេងៗអាចមើលឃើញបន្ទាត់ណាមួយ រួចនិយាយប្រយោគ នៃការសួស្តីគ្នា។ សកម្មភាពនេះអាចប្តូរដោយប្រើជាប្រយោគផ្សេងទៀតដែលក្មេងបានរៀននៅសាលារៀនបាន។